USAID | CAMBODIA
FROM THE AMERICAN PEOPLE

សេចក្តីប្រកាសព័ត៌មាន ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៥

# ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) បានចុះហត្ថលេខាថ្មីមួយជាមួយ Development Alternatives, Inc. ដើម្បីអនុវត្តគំរោងស្តីពីការពង្រឹងនូវមីក្រូសេដ្ឋកិច្ចសហគ្រាសខ្នាតតូច និង មធ្យមនៅកម្ពុជា

នៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៥ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងថ្មីមួយជាមួយ Development Alternatives, Inc. ក្នុងការអនុវត្តគំរោងរយៈពេល៣ឆ្នាំដែលមានចំនួនថវិកាសរុប ៤,៥ លានដុល្លារសហរដ្ឋអាមេរិក ដើម្បីពង្រឹងនូវមីក្រូសេដ្ឋកិច្ចសហគ្រាសខ្នាតតូច និង មធ្យមនៅក្នុងវិស័យឯកជនកម្ពុជា ។

គំរោងនេះត្រូវបានបង្កើតឡើងដើម្បីពង្រឹងនូវមីក្រូសេដ្ឋកិច្ចសហគ្រាសខ្នាតតូច និង ធម្យមនៅកម្ពុជា ។ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិប្រចាំនៅកម្ពុជា (USAID/Cambodia) បានស្វែងរកនូវការឆ្នៃប្រឌិតបង្កើតធនធានក្នុងសហគមន៍ក្រីក្រ និង ជំរុញឱ្យវិស័យឯកជនកាន់តែកើនឡើង ដោយធ្វើឱ្យមានការទំនាក់ទំនងគ្នានូវសហគ្រាសខ្នាតតូច និង ធម្យម ដែលមានចំនួនដ៏លើសលុបទាំងឱ្យមាននិរន្តភាព ដែលកំពុងរីកលូតលាស់នៅតាមមូលដ្ឋាន តំបន់ រឺ ក៏នៅក្នុងទីផ្សារ អន្តរជាតិ ហើយនៅតែកំពុងបន្តការងារដើម្បីដោះស្រាយនូវសម្ពាធបរិយាកាសនៃការធ្វើពាណិជ្ជកម្មនៅកម្ពុជា ។

USAID ប្រចាំនៅកម្ពុជាមានគោលបំណងក្នុងការធ្វើឱ្យកើនឡើងនូវប្រភពចំណូលសំរាប់ សេដ្ឋកិច្ចសហគ្រាសខ្នាតតូច និង មធ្យមនៅកម្ពុជា ដើម្បីសង្កត់ធ្ងន់ទៅលើកំនើនសេដ្ឋកិច្ច និង ធ្វើឱ្យប្រសើរឡើងលើអភិបាលកិច្ចនៃសេដ្ឋកិច្ចជាប្រព័ន្ធ និង ជាផ្លូវដែលជាកម្លាំងជំរុញសំរាប់ការអភិវឌ្ឍន៍នៅកម្ពុជា ។ យុទ្ធសាស្ត្រជាក់លាក់របស់ USAID ប្រចាំនៅកម្ពុជា សង្កត់ធ្ងន់ទៅលើប្រសិទ្ធិភាពក្នុងការរៀបចំវិស័យឯកជនដែលអាចរីកលូតលាស់កាន់តែធំ និង ពង្រឹងនូវសិទ្ធបញ្ចេញមតិរបស់សង្គមស៊ីវិលនៅក្នុងកម្ពុជា បង្ហាញឱ្យឃើញពីការទទួលខុសត្រូវ និង មានតម្លាភាព ដែលហៅថា

អភិបាលកិច្ចល្អ ។ ហើយក៏ពង្រឹងនូវសមត្ថភាពរបស់ប្រជាជនកម្ពុជាផងដែរ ក្នុងការចូលរួមចំណែកក្នុងសកម្មភាពសេដ្ឋកិច្ច និង នយោបាយ ឱ្យកាន់តែមានប្រសិទ្ធភាពដែលជាដួងប្រលឹងរបស់ប្រទេស ។

ដើម្បីធ្វើឱ្យប្រាកដឡើងពីការពង្រីកឥទ្ធិពលនៃការរីកលូតលាស់ USAID ប្រចាំនៅកម្ពុជា នឹងធ្វើការផ្តោតទៅលើកន្លែងណាដែលភាពក្រីក្រត្រូវបានយកចិត្តទុកដាក់ ដែលមានឈ្មោះថាវិស័យខាងកសិកម្ម និង មិនផ្លូវការ ។ នឹងផ្តល់ការយកចិត្តទុកដាក់យ៉ាងពិសេសទៅលើគ្រួសារណាដែលជាម្ចាស់ខាងវិស័យកសិកម្មនៅជនបទ ហើយផ្តោតទៅលើការធ្វើអាជីវកម្មខ្នាតតូច ។ គំរោងនេះនឹងត្រូវបានបង្កើតឡើង ដរាបណា USAID នៅតែបន្តការធ្វើការងារទៅលើការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និង ធម្យមនេះ ការអភិវឌ្ឍន៍ឥណ្ឌទាន និង ការសិក្សាស្ថាប័នដែលផ្តល់ឥណ្ឌទានផងដែរ។ ម្យ៉ាងទៀត USAID ក៏បានធ្វើការជាមួយស្ថាប័នផ្ចួចផ្តើមផ្សេងៗទៀត នៅក្នុងការពង្រឹងនូវមីក្រូសេដ្ឋកិច្ចសហគ្រាសខ្នាតតូច និង មធ្យម នៅកម្ពុជាផងដែរ។

គំរោងបីឆ្នាំត្រូវអនុវត្តក្នុងប្រទេសកម្ពុជានេះ គ្រោងនឹងចាប់ផ្តើមក្នុង ខែតុលា ឆ្នាំ ២០០៥ នេះ ។

*ពត៌មានបន្ថែម សូមទំនាក់ទំនងការិយាល័យកិច្ចការសាធារណៈរបស់ស្ថានទូតសហរដ្ឋអាមេរិក ទូរស័ព្ទលេខៈ ៨៥៥-០២៣- ២១៦ ៤៣៦/៣៨ ។*